ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

លេខ : ១៩០......... ស.កបក

# សារាចរណ៍

ដោយពិនិត្យឃើញថាបច្ចុប្បន្ននេះ បរិមាណបុគ្គលិកបច្ចេកទេសសុខាភិបាលទាំងនៅភ្នំពេញ ទាំងនៅតាមខេត្តក្រុងទាំងអស់ក្នុងទូទាំងប្រទេសបានឈានដល់កំរិតមួយដែលអាចផ្តល់លទ្ធភាពឲ្យមូលដ្ឋានជំរុញការពង្រឹងការងារដឹកនាំនិងគ្រប់គ្រងបណ្តាញសុខាភិបាលចំណុះមន្ទីរសុខាភិបាលខេត្ត-ក្រុង ជាពិសេស បណ្តាញថ្នាក់ ស្រុកនិងឃុំ ដែលរហូតមកដល់ពេលនេះមានស្រុកនិងឃុំមួយចំនួនធំនៅខ្សោយនៅ ឡើយ ។

ដោយគោលនយោបាយសុខាភិបាលជាតិឆ្នាំ១៩៩៤-១៩៩៦និងបណ្តាឆ្នាំខាងមុខបានកំណត់យ៉ាងច្បាស់អំពីទិសដៅអភិវឌ្ឍន៍វិស័យសុខាភិបាលនៅជនបទជាសំខាន់ ។

ដើម្បីបោះជំហានឲ្យស្របតាមផែនការអភិវឌ្ឍន៍ខាងលើនេះ ក្រសួងសុខាភិបាលកំណត់គោលការណ៍ណែនាំអនុវត្តការងារមួយចំនួនដូចខាងក្រោម ÷

- នៅថ្នាក់ស្រុក ការិយាល័យសុខាភិបាលនិងមន្ទីរពេទ្យស្រុក ត្រូវដឹកនាំនិងគ្រប់គ្រងដោយគ្រូពេទ្យមធ្យម ប៉ុន្តែបើស្រុកធំ មានឃុំនិងប្រជាពលរដ្ឋច្រើន ត្រូវដាក់ឲ្យវេជ្ជបណ្ឌិតគ្រប់គ្រង ។

- នៅថ្នាក់ឃុំ គិលានដ្ឋានឃុំ ត្រូវដឹកនាំដោយគិលានុបដ្ឋាក យិកា ឬ ឆ្មប មធ្យម ប៉ុន្តែប្រសិនបើឃុំធំ ត្រូវដឹកនាំដោយគ្រូពេទ្យមធ្យម ។

មន្ទីរសុខាភិបាលខេត្ត-ក្រុងមានសិទ្ធិតែងតាំង , ផ្លាស់ប្តូរ និងកែសំរួលភារកិច្ចមន្ត្រីដឹកនាំគ្រប់គ្រងបណ្តាញចំណុះ ដោយស្មារតីទទួលខុសត្រូវ មិនចាំបាច់ស្នើសុំតែងតាំងនិងសុំយោបល់ពីក្រសួងឡើយ តែត្រូវចំលងមួយច្បាប់ ជូនក្រសួងសុខាភិបាលនិងអភិបាលខេត្ត-ក្រុង ដើម្បីជារបាយការណ៍ ។ ក្រសួងក៏រំលឹកដែរថា ក្នុងការ

តែងតាំងជាមន្ត្រីដឹកនាំ ត្រូវជ្រើសរើសយកមន្ត្រីដែលសមត្ថភាពការងារ មាន សីលធម៌វិជ្ជាជីវៈខ្ពស់ និងមានប្រជាជនស្រលាញ់រាប់អានច្រើន ។

ម្យ៉ាងទៀត ដើម្បីលើកទឹកចិត្តឲ្យមន្ត្រីសុខាភិបាលស្ម័គ្រចិត្តទៅបំរើការនៅមូលដ្ឋាន មន្ទីរសុខាភិបាលខេត្ត-ក្រុងត្រូវខិតខំយកចិត្តទុកដាក់ឲ្យអស់លទ្ធភាពក្នុងការផ្តល់មធ្យោបាយស្នាក់នៅដល់បុគ្គលិកដែលបញ្ជូនទៅថ្មី ដែលគ្មានកន្លែងស្នាក់នៅ ។ ប្រសិនបើមានគំរោងសាងសង់មន្ទីរពេទ្យស្រុកឬគិលានដ្ឋានឃុំថ្មីត្រូវយកចិត្តទុកដាក់ធ្វើគំរោងពីទីកន្លែងស្នាក់នៅរបស់បុគ្គលិកផង ។

ភ្នំពេញថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៤

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់អភិបាលខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- នាយកដ្ឋានសុខាភិបាល
- ឯកសារ

---

ក្រសួងសុខាភិបាល

លេខ......ស.ក.ប

ច្បាប់ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ដើម្បីផ្សព្វផ្សាយតទៅ ។

ភ្នំពេញ ថ្ងៃទី ខែ មិថុនា ១៩៩៥

ជ.រដ្ឋមន្ត្រីក្រសួងសុខាភិបាល